# របៀបដាក់ពាក្យចូលសាលារៀន

## 1　របៀបដាក់ពាក្យប្តូរសាលារៀន

នៅពេលដែលចង់ប្តូរសាលាកូនចូលរៀនបឋមសិក្សាឬអនុវិទ្យាល័យជប៉ុននោះគឺសូមនាំកូននឹងអ្នកចេះនិយាយភាសារជប៉ុនមកជាមួយដើម្បីដាក់ពាក្យនៅមន្ទីរគណៈកម្មាធិការអប់រំផ្នែកកិច្ចការសិក្សា។បន្ទាប់ពីបំពេញសំណុំពាក្យហើយគឺអាណាព្យាបាលត្រូវនាំសិស្សទៅសាលាដែលត្រូវប្តូរចូលនោះតាមថ្ងៃកំណត់របស់សាលាដើម្បីចូលរួមស្តាប់ការពន្យល់របស់នាយកសាលានិងគ្រូប្រចាំថ្នាក់ពីវិន័យសាលានឹងត្រៀមសំភារះដែលចាំបាច់ប្រើប្រាស់ក្នុងសាលា។

## 2　របៀបដាក់ពាក្យចុះឈ្មោះចូលសាលារៀនដំបូង

បើចង់អោយកូនចូលរៀនសាលាបឋមសិក្សានឹងអនុវិទ្យាល័យចាប់ពីខែ 4 ទៅនោះគឺនៅឆ្នាំមុនកំឡុងខែ 9 នោះគណៈកម្មាធិកាផ្នែកអប់រំបានផ្ញើសំបុត្រជូនដំណឹងចូលសាលារៀនតាមប្រៃសណីយ៍,ដូច្នេះសូមយកសំបុត្រនោះមកជាមួយចុះឈ្មោះចូលរៀននៅមន្ទីរគណៈកម្មាធិការអប់រំផ្នែកកិច្ចការសិក្សា។

កាលវិភាគមុនចូលរៀន

| កំឡុងពេល | សាលាបឋមសិក្សា | អនុវិទ្យាល័យ |
|---|---|---|
| កំឡុងខែ １１ | លិខិតណែនាំស្តីពីការពិនិត្យសុខភាពនឹងត្រូវផ្ញើតាមប្រៃសណីយ៍ | |
| ពាក់កណ្តាលខែ １２ | សូមរក្សាទុកលិខិតជូនដំណឹងចូលសាលារៀនរហូតត្រឹមថ្ងៃចូលរៀន | |
| ពីខែ １～ខែ ２ | ចូលរួមស្តាប់ការពន្យល់នឹងណែនាំពីការរៀបចំសំរាប់ការចូលរៀនដំបូង | |
| ខែ ４ | ប្រារព្ធពិធីចូលសាលារៀន<br>សូមនាំកូនមកសាលាព្រមទាំងកាន់លិខិតជូនដំណឹងចូលសាលាមកជាមួយផង | |

＊ ចំពោះជនបរទេសដែលមិនបានចុះឈ្មោះបញ្ជីស្នាក់នៅក្នុងសង្កាត់ទេហើយចង់អោយកូនប្តូរចូលរៀនសាលាបឋមសិក្សានឹងអនុវិទ្យាល័យនោះសូមទូរស័ព្ទទៅកាន់ផ្នែកកិច្ចការសិក្សា។


កន្លែងទាក់ទង　　គណៈកម្មាធិការអប់រំក្រុងសាហ្គាមីហារ៉ា

ផ្នែកកិច្ចការសិក្សា　（ផ្នែកគ្រប់គ្រងការចូលរៀន）

ទូរស័ព្ទលេខ：０４２（７６９）８２８２